# Epilepsy Australia

អង្គការជម្ងឺស្កន់ធំជាងគេដឹកនាំដោយអតិថិជននៃប្រទេសអូស្ត្រាលី


### Epilepsy Australia Ltd

ការិយាល័យធំ

818 – 822 Burke Road
Camberwell Vic 3124

ទូរស័ព្ទ: 03 9805 9111

ទូរសារ: 03 9882 7159

epilepsy@epilepsyaustralia.net
www.epilepsyaustralia.net

### Epilepsy ACT

27 Mulley St Holder ACT 2611

ទូរស័ព្ទ: 02 6287 4555

ទូរសារ: 02 6287 4556

epilepsy@epilepsyact.org.au
www.epilepsyact.org.au

### Epilepsy Australia in NSW

PO Box 1049 Baulkham Hills NSW 2153

ទូរស័ព្ទ: 02 9674 9966

ទូរសារ: 02 9620 7087

epilepsy@epilepsyaustralia.net

### The Epilepsy Centre

266 Port Rd Hindmarsh SA 5007

ទូរស័ព្ទ: 08 8445 6131

ទូរសារ: 08 8445 6387

enquiries@epilepsycentre.org.au
www.epilepsycentre.org.au

### Epilepsy Association of Tasmania Inc

PO Box 562 Burnie Tas 7320

ទូរស័ព្ទ: 03 6431 7848

ទូរសារ: 03 6431 5566

etas.nw@bigpond.net.au
www.epilepsytasmania.org

### Epilepsy Association of Western Australia Inc

The Niche
11 Aberdare Rd Nedlands WA 6009

ទូរស័ព្ទ: 08 9346 7699

ទូរសារ: 08 9346 7696

epilepsy@cnswa.com
www.epilepsywa.org.au

### Epilepsy Foundation of Victoria

818 Burke Rd Camberwell Vic 3124

ទូរស័ព្ទ: 03 9805 9111

ទូរសារ: 03 9882 7159

epilepsy@epilepsy.asn.au
www.epinet.org.au

### Epilepsy Queensland Inc

Level 2 Gabba Towers
411 Vulture Street Woolloongabba Qld 4102

ទូរស័ព្ទ: 07 3435 5000

ទូរសារ: 07 3435 5025

epilepsy@epilepsyqueensland.com.au
www.epilepsyqueensland.com.au


ចំពោះព័ត៌មានបន្ថែមស្ដីអំពីជម្ងឺស្កន់ ការព្យាបាល និងការគ្រប់គ្រង សូមទូរស័ព្ទ

**1300 852 853**


ប្រយោគបដិសេធ: ក្នុងខណៈដែលព័ត៌មាននៅក្នុងកូនសៀវភៅនេះ តាមដែលយើងបានដឹងច្បាស់បំផុតថាវាមានភាពត្រឹមត្រូវ ហើយមានប្រយោជន៍ វាពុំមែនមានន័យសំរាប់ដាក់ជំនួសការទាក់ទងផ្ទាល់ជាមួយសហគមជម្ងឺស្កន់ដែលមានមូលដ្ឋាននៅតាមសហគមន៍ ឬជាមួយអ្នកជំនាញវិជ្ជាជីវៈផ្នែកសុខភាពឡើយ។


Cambodian

# ការជួយសង្គ្រោះជាបន្ទាន់ ចំពោះករណី រោគប្រកាច់


These translations funded by
The Ian Potter Foundation
The Helen Macpherson Smith Trust




Epilepsy Australia

អង្គការជម្ងឺស្កន់ធំជាងគេដឹកនាំដោយអតិថិជននៃប្រទេសអូស្ត្រាលី

## ■ រោគប្រកាច់ចលនាសរីរាង្គសាច់ដុំ(ពីមុនគេស្គាល់ថាជាការឈឺជីខ្លាំងក្លា)

រោគប្រកាច់ចលនាសរីរាង្គសាច់ដុំ គឺជារោគប្រកាច់ដោយទូទៅទាក់ទិននឹងខួរក្បាលទាំងមូល។ នេះគឺជាប្រភេទនៃរោគប្រកាច់ដែលមនុស្សភាគច្រើនគិតឃើញ នៅពេលគេគិតអំពីជម្ងឺស្កន់។ អ្នកខ្លះអាចមានបទពិសោធន៍ដូចជាមានអារម្មណ៍ដែលគេអាចសំគាល់ដឹងខ្លួនឯង ដូចជាមានអារម្មណ៍បានជួបប្រទះពីពេលមុនៗ មានអារម្មណ៍មិនស្រួលក្នុងពោះ មានរសជាតិ ឬក្លិនចំឡែក មុនពេលរោគប្រកាច់ចាប់ផ្តើម។ អារម្មណ៍ដែលគេអាចសំគាល់ដឹងខ្លួនឯង គឺជារោគប្រកាច់ដោយផ្នែកសាមញ្ញ។



*រោគប្រកាច់ដែលទាក់ទិននឹងខួរក្បាលទាំងមូល គេហៅថារោគប្រកាច់ដោយទូទៅបឋម។*

ក្នុងរយៈពេលកើតរោគប្រកាច់ចលនាសរីរាង្គសាច់ដុំ ខ្លួនប្រាណរបស់មនុស្សបានស្ពឹកស្រពន់ ហើយដួលទៅលើដី (ដំណាក់កាលចលនាសាច់ដុំ)។ អវៈយវៈរបស់គេចាប់ផ្តើមញាក់ដោយចលនាជាចង្វាក់ស៊ីគ្នា ហើយខ្លាំង (ដំណាក់កាលសរីរាង្គសាច់ដុំ)។ មនុស្សនោះអាចហៀរទឹកមាត់ មុខឡើងខៀវ ឬក្រហម ឬពុំអាចគ្រប់គ្រងតម្រងនោម និង/ឬពោះវៀនរបស់គេ។

ថ្វីត្បិតតែរោគប្រកាច់ប្រភេទនេះមើលទៅឃើញគួរឲ្យភ័យខ្លាចក្តី រោគប្រកាច់ពុំធ្វើឲ្យមានគ្រោះថ្នាក់ដល់មនុស្សដែលកើតរោគប្រកាច់នេះទេ។ ទោះជាយ៉ាងណាក៏ដោយ គេប្រហែលជាក្អួត ឬខាំអណ្តាតរបស់គេ ហើយជួនកាលអាចធ្វើឲ្យមានរបួសដល់ខ្លួនឯង ប្រសិនបើបើគេប៉ះទង្គិចនឹងវត្ថុនៅក្បែរដោយសារដួលញាក់ ឬកន្ត្រាក់។ តាមធម្មតា រោគប្រកាច់ឈប់ចំនួន២-៣នាទីក្រោយមក។ នៅពេលនោះ តាមធម្មតាមនុស្សច្រឡំបល់ ហើយងងុយដេក។ គេអាចមានការឈឺក្បាល ហើយចង់ដេក។ ភាពងងុយដេកនេះអាចមានរយៈពេលជាច្រើនម៉ោង។

## ■ រោគប្រកាច់ចលនាសាច់ដុំដោយទូទៅ

រោគប្រកាច់ចលនាសាច់ដុំ គឺជារោគប្រកាច់ដោយទូទៅដែលធ្វើឲ្យសាច់ដុំស្ពឹកស្រពន់ ហើយប្រសិនបើមនុស្សនោះកំពុងឈរ គេនឹងដួលយ៉ាងធ្ងន់ធ្ងរទៅលើដី។ រោគប្រកាច់ទាំងនេះអាចកើតមានជាពួកជាក្រុមនៅពេលដេក ក៏ប៉ុន្តែប្រសិនបើកើតមាននៅពេលមនុស្សក្រោកពីដេក ជាញឹកញយវាអាចបណ្តាលឲ្យមានរបួសក្បាល។ ប្រសិនបើជាការសមរម្យ គួរឲ្យមនុស្សនោះពាក់មួកការពារក្បាលដើម្បីជៀសវាងការរបួស។ សូមស្វែងរកការព្យាបាលខាងផ្នែកពេទ្យ ប្រសិនបើមនុស្សនោះមានរបួស។

## ■ រោគប្រកាច់ចលនាសាច់ដុំ

រោគប្រកាច់ចលនាសាច់ដុំដោយទូទៅ គឺជារោគប្រកាច់ដោយទូទៅ ដែលប៉ះពាល់ដល់កម្លាំងកន្ត្រាក់សាច់ដុំធ្វើឲ្យមនុស្សនោះដួលទៅលើដី។ ជាញឹកញយ គេហៅវាថារោគប្រកាច់ដួល ឬរោគប្រកាច់មិននៅនឹងកន្លែង រោគប្រកាច់ទាំងនេះអាចបណ្តាលឲ្យមានរបួសក្បាល ឬមុខ។ គួរពាក់វត្ថុការពារក្បាលដើម្បីជៀសវាងកុំឲ្យមានរបួសជារៀងរាល់ពេល។ តាមធម្មតា ការជាឡើងវិញកើតអាចកើតមានឡើងយ៉ាងឆាប់រហ័ស។ សូមស្វែងរកការព្យាបាលខាងផ្នែកពេទ្យ ប្រសិនបើមនុស្សនោះមានរបួស។



# ការជួយសង្គ្រោះជាបន្ទាន់ចំពោះករណីរោគប្រកាច់

អ្វីដែលត្រូវធ្វើនៅពេលនរណាម្នាក់កើតរោគប្រកាច់ គឺអាស្រ័យទៅលើប្រភេទនៃរោគប្រកាច់ដែលជននោះកើតមាន។

## ■ រោគប្រកាច់ចលនាសរីរាង្គសាច់ដុំ

រោគញាក់ប្រកាច់ ឬរោគប្រកាច់ចលនាសរីរាង្គសាច់ដុំ ចាប់ផ្តើមនៅពេលអ្នកណាម្នាក់បាត់បង់ស្មារតីស្ពឹកស្រពន់ដោយពុំបានគិតទុកមុន ដួលទៅលើដី ហើយចាប់ផ្តើមកន្ត្រាក់ញ្ញោចៗ។

### របៀបជួយ:

- ✓ នៅជាមួយមនុស្សនោះ - នៅឲ្យស្ងៀម។
- ✓ សង្កេតមើលរយៈពេលនៃការកើតរោគប្រកាច់។
- ✓ ការពារកុំឲ្យមានរបួស - យកវត្ថុរឹងចេញពីកន្លែងនោះ។ ដាក់វត្ថុអ្វីដែលទន់នៅក្រោមក្បាលរបស់គេ។ បន្ធូរសម្លៀកបំពាក់ដែលរឹតតឹង។
- ✓ រមៀលមនុស្សនោះដោយថ្នមៗឲ្យទៅម្ខាងខ្លួន - ឲ្យបានឆាប់ដែលអាចធ្វើទៅបាន ដើម្បីជួយនៅក្នុងការដកដង្ហើម។
- ✓ បង្កើតការទំនាក់ទំនងដើម្បីឲ្យលោកអ្នកដឹងថាគេប្រាកដជាមានស្មារតីដឹងខ្លួនឡើងវិញ។
- ✓ ឲ្យមនុស្សនោះមានទំនុកទុកចិត្តជាថ្មី។
- ✓ ឲ្យមនុស្សទាំងឡាយដែលនៅក្បែរ ដើរចេញពីទីនោះ។

- ✘ កុំ ឃាត់ឃាំងចលនារបស់មនុស្សនោះ។
- ✘ កុំ បង្ខំដាក់អ្វីទៅក្នុងមាត់។
- ✘ កុំ ឲ្យមនុស្សនោះពិសាទឹក ថ្នាំលេប ឬចំណីអាហារ រហូតទាល់តែគេដឹងខ្លួនពេញលេញ។

បន្ទាប់ពីផុតកើតមានរោគប្រកាច់ហើយ ត្រូវដាក់មនុស្សនោះនៅខាងឆ្វេងរបស់គេ។ ត្រូវចងចាំទុកថាអាចកើតមានការក្អួតបន្តិចបន្តួច ក្រោយពីការកើតរោគប្រកាច់ មុនពេលដែលមនុស្សនោះបានដឹងខ្លួនពេញលេញ។ ដោយហេតុនេះ ត្រូវដាក់ក្បាលមនុស្សនោះផ្អៀង ដើម្បីឲ្យកំអួតហូរចេញពីមាត់ ហើយការពារកុំឲ្យស្រូបចូលទៅក្នុងសួត។ នៅជាមួយមនុស្សនោះ រហូតទាល់តែគេបានជាសះស្បើយ (៥ ទៅ២០នាទី)។

## ទូរស័ព្ទហៅឡានពេទ្យលេខ 000 ប្រសិនបើ:

- ✓ សកម្មភាពរោគប្រកាច់មានរយៈពេលយូរជាង៥នាទី ឬរោគប្រកាច់ទី២កើតមានបន្ទាប់ទៀត យ៉ាងរហ័ស។
- ✓ មនុស្សនោះនៅតែពុំដឹងខ្លួន ក្នុងរយៈពេល៥នាទីដែលរោគប្រកាច់បានឈប់។
- ✓ រោគប្រកាច់កើតមាននៅក្នុងទឹក។
- ✓ ជនដែលកើតរោគប្រកាច់នោះមានរបួស។
- ✓ មនុស្សនោះមានផ្ទៃពោះ ឬមានរោគទឹកនោមផ្អែម។
- ✓ លោកអ្នកដឹង ឬជឿថាមនុស្សនោះមានរោគប្រកាច់លើកដំបូង។
- ✓ លោកអ្នកមានការសង្ស័យ។

## រោគប្រកាច់ដោយផ្នែកស្មុគស្មាញ

ជាមួយនឹងរោគប្រកាច់ប្រភេទនេះ មនុស្សនោះឃើញហាក់ដូចជាពុំឆ្លើយតប ហើយច្រឡំបល់។ បង្ហាញឲ្យឃើញចលនាស្វ័យប្រវត្តិដូចជាវាយទះបបូរមាត់ មានដំណើរទ្រេតទ្រោត ឬមានចលនាទំលាក់ដៃចុះ។ គេអាចបង្ហាញឲ្យឃើញនូវអាកប្បកិរិយាពុំសមរម្យដែលធ្វើឲ្យច្រឡំនឹងការស្រវឹងស្រា ឬការពុលគ្រឿងញៀន។

- ✓ ក្នុងរយៈពេលមានរោគប្រកាច់ដោយផ្នែកស្មុគស្មាញ លោកអ្នកអាចតំរង់នាំផ្លូវមនុស្សនោះដោយថ្នមៗចេញឲ្យផុតពីឧបស័គ្គ ហើយទៅឲ្យឆ្ងាយពីទីកន្លែងមានគ្រោះថ្នាក់។
- ✓ ក្រោយពីរោគប្រកាច់បានកន្លងផុតហើយ ចូរបង្កើតនូវការឆ្លើយឆ្លងដែលមានការជួយទ្រទ្រង់ ហើយសាកសួរប្រសិនបើគេបានជាស្រួលបួលឡើងវិញ។
- ✓ ទូរស័ព្ទហៅឡានពេទ្យ ប្រសិនបើមនុស្សនោះពុំបានចាប់ផ្តើមស្រួលខ្លួនឡើងវិញបន្ទាប់ពី១៥នាទីក្រោយមក។

## រោគប្រកាច់អវត្តមាន

រោគប្រកាច់អវត្តមានធ្វើឲ្យបាត់បង់ការដឹងខ្លួនក្នុងរយៈពេលដ៏ខ្លី។ មនុស្សនោះសំឡឹងដោយមិនដឹងខ្លួន ភ្នែកបញ្ឈរឡើងលើ ហើយព្រិចបើកៗ។ អាចមានការច្រឡំថាគេមានការស្រមើស្រមៃ។ ត្រូវទទួលស្គាល់ថារោគប្រកាច់បានកើតឡើង ហើយធ្វើឲ្យជននោះមានទំនុកទុកចិត្តឡើងវិញ ហើយរំលឹកឡើងវិញនូវព័ត៌មានទាំងឡាយណាដែលអ្នកនោះអាចបាត់បង់ ក្នុងរយៈពេលគេកើតរោគប្រកាច់។

## ការជួយសង្គ្រោះជាបន្ទាន់ចំពោះករណីរោគប្រកាច់នៅក្នុងទឹក

នៅក្នុងស្ថានភាពជាក់លាក់ទាំងឡាយ ការបាត់បង់ស្មារតីគឺជាការគ្រោះថ្នាក់ណាស់ ហើយការមើលថែជាបន្ទាន់ត្រូវតែធ្វើឡើងលើសពីទម្រង់ការដដែលៗធម្មតា។ រោគប្រកាច់នៅក្នុងទឹកគឺជាស្ថានភាពមួយដែលមានការគំរាមកំហែងដល់ជីវិត។

ប្រសិនបើនរណាម្នាក់កើតរោគប្រកាច់នៅក្នុងទឹក ឧទាហរណ៍: ក្នុងអាងងូតទឹក ឬក្នុងអាងហែលទឹក:

- ✓ ជួយទ្រទ្រង់មនុស្សនៅក្នុងទឹក ដោយផ្អៀងក្បាលដើម្បីឲ្យមុខ និងក្បាលនៅផុតពីផ្ទៃទឹក។
- ✓ យកមនុស្សនោះចេញពីទឹក ឲ្យបានយ៉ាងឆាប់ដែលអាចធ្វើទៅបាន ពេលណាចលនាសកម្មនៃរោគប្រកាច់បានឈប់។
- ✓ ពិនិត្យមើលថាតើមនុស្សនោះដកដង្ហើមឬទេ បើអត់ទេ ចាប់ផ្តើមការជួយសង្គ្រោះជាបន្ទាន់ (CPR)។
- ✓ ទូរស័ព្ទហៅឡានពេទ្យ ទោះថាមនុស្សនោះមើលទៅហាក់ដូចជាសះស្បើយពេញលេញក៏ដោយ គេត្រូវការពិនិត្យមើលសុខភាពឲ្យបានពេញលេញ។ ការបឺតស្រូបទឹកអាចបណ្តាលឲ្យខូចសួត ឬបេះដូង។

ការប្រុងប្រយ័ត្ន: ប្រសិនបើរោគប្រកាច់កើតឡើងនៅក្នុងទឹក នៅពេលកំពុងមានសកម្មភាពហែលទឹក មនុស្សនោះមិនត្រូវបន្តការហែលទឹក ឬក៏ឡាក្នុងទឹកនៅថ្ងៃនោះទេ ទោះថាមនុស្សនោះមើលទៅដូចជាសះស្បើយពេញលេញក៏ដោយ។






*រោគប្រកាច់ និងជម្ងឺស្កន់ជួនកាលមានឈ្មោះយោលទៅតាមក្លែបខួរក្បាល ឬផ្នែកនៃខួរក្បាលដែលសកម្មភាពរោគប្រកាច់មានប្រភពចេញមក។*

## ■ រោគប្រកាច់ដោយផ្នែកស្មុគស្មាញ

រោគប្រកាច់ប្រភេទនេះប៉ះពាល់តែផ្នែកមួយនៃខួរក្បាលប៉ុណ្ណោះ ក៏ប៉ុន្តែសភាពដឹងខ្លួននៃមនុស្សនោះត្រូវបានផ្លាស់ប្តូរ។ អ្នកជម្ងឺមើលទៅដូចជាច្រឡំបល់ និងភាំងស្មារតី ហើយអាចធ្វើសកម្មភាពចំឡែកដូចជាចាប់ច្បិចខោអាវលេង ធ្វើចលនាទំពារ ឬបញ្ចេញសម្លេងមិនធម្មតា។ ធម្មតា រោគប្រកាច់មានរយៈពេល១-២នាទី ក៏ប៉ុន្តែមនុស្សនោះអាចច្រឡំបល់ ហើយងងុយដេកចំនួនប៉ុន្មាននាទី ទៅច្រើនម៉ោងក្រោយមក។

## ■ រោគប្រកាច់អវត្តមាន (ពីមុនគេស្គាល់ថាការឈឺតូចតាច)

នេះគឺជារោគប្រកាច់ទូទៅដែលទាក់ទិននឹងខួរក្បាលទាំងមូល ហើយធម្មតាតែងកើតមានជាទូទៅនៅក្នុងចំណោមកូនក្មេង។ ជាមួយនឹងរោគប្រកាច់ប្រភេទនេះ មនុស្សបាត់បង់នូវការដឹងអំពីអ្វីដែលកើតមាននៅជុំវិញគេ ក៏ប៉ុន្តែគេកម្រដួលទៅលើដីណាស់។ គេគ្រាន់តែសម្លក់ ហើយភ្នែករបស់គេបញ្ឈរទៅក្រោយ ឬត្របកភ្នែករបស់គេបក់ញាប់ញ័រប៉ុណ្ណោះ។

មានការពិបាកក្នុងការដឹងពីភាពខុសគ្នារវាងរោគប្រកាច់អវត្តមាន និងការស្រមើស្រមៃ ទោះជាយ៉ាងណាក្តី រោគប្រកាច់អវត្តមានចាប់ផ្តើមភ្លាមមួយរំពេចអស់រយៈពេល២-៣វិនាទី រួចមកឈប់មួយរំពេច ហើយមនុស្សនេះក៏ចាប់បន្តកិច្ចការដែលគេកំពុងធ្វើតទៅទៀត។ ថ្វីត្បិតតែរោគប្រកាច់នេះមានរយៈពេលតែប៉ុន្មានវិនាទីក៏ដោយ វាអាចកើតមានជាច្រើនដងក្នុង១ថ្ងៃ ហេតុដូច្នេះវាធ្វើឲ្យមានការរំខានដល់ការរៀនសូត្រ។

## ■ រោគប្រកាច់ញាក់សាច់ដុំ

រោគប្រកាច់ញាក់សាច់ដុំគឺជាការញាក់សាច់ដុំដែលមិនអាចគ្រប់គ្រងបាន។ តាមធម្មតា រោគប្រកាច់នេះកើតមានមិនយូរប៉ុន្មានក្រោយភ្ញាក់ពីដំណេក ឬមុនចូលដេក នៅពេលមនុស្សនោះអស់កម្លាំង។ ដូចគ្នានឹងរោគប្រកាច់ដោយទូទៅដែរ ការបាត់បង់ស្មារតីកើតមានឡើង ក៏ប៉ុន្តែវាមានរយៈពេលខ្លី ហើយសឹងតែមិនអាចកត់សម្គាល់ឃើញ។

## តើអ្វីជាជម្ងឺស្កន់?

ជម្ងឺស្កន់គឺជាវិបល្លាសនៃចលនាខួរក្បាល មានទ្រង់ទ្រាយរោគប្រកាច់កើតមានជារឿយៗ។

## តើអ្វីជារោគប្រកាច់?

រៀងរាល់ការគិត ការទទួលអារម្មណ៍ ឬប្រតិកម្មរបស់យើងត្រូវបានគ្រប់គ្រងដោយកោសិកាដែលទាក់ទងគ្នាទៅវិញទៅមកតាមរយៈកម្លាំងសន្ទុះអគ្គីសនី។ រោគប្រកាច់កើតឡើងនៅពេលកើតមានការផ្ទុះភ្លាមៗនៃសកម្មភាពអគ្គីសនីដែលបង្អាក់អាកប្បកិរិយានេះ។ ទំនាក់ទំនងរវាងកោសិកាទៅជាមានចលនាច្របូកច្របល់គ្នា ហើយការគិត ការទទួលអារម្មណ៍ ឬចលនាក្លាយទៅជាច្របូកច្របល់ ឬមិនអាចគ្រប់គ្រងបានភ្លាមៗ។

ក្នុងខណៈដែលរោគប្រកាច់អាចធ្វើឲ្យមានការភ័យខ្លាច នៅក្នុងករណីយភាគច្រើន រោគនេះអាចឈប់ដោយពុំមានការធ្វើអន្តរាគមន៍។ នៅពេលរោគប្រកាច់បានឈប់ហើយ ជនដែលប្រកាច់នោះក៏មានអារម្មណ៍ស្រួលបួលឡើងវិញដោយគ្មានផលឈឺចាប់អ្វីណាមួយទេ។ មនុស្សភាគច្រើនដែលបានទទួលរោគវិនិច្ឆ័យ ហើយកើតមានជម្ងឺស្កន់ នឹងមានថ្នាំព្យាបាលដើម្បីបង្ក្រាបរោគប្រកាច់របស់គេ។

### ការទទួលស្គាល់នូវរោគប្រកាច់

មានការយល់ព្រមជាអន្តរជាតិថា ក្នុងខណៈដែលរោគប្រកាច់មានភាពស្មុគស្មាញ ជាទូទៅវាមានពីរជំពូកៈ ម្យ៉ាងគឺដោយផ្នែក ឬនៅចំកណ្តាល ហើយម្យ៉ាងទៀតគឺដោយទូទៅ។ រោគប្រកាច់ដោយផ្នែក ឬនៅចំកណ្តាលចាប់ផ្តើមនៅក្នុងផ្នែកមួយនៃខួរក្បាល (ពោលគឺនៅចំកណ្តាលក្នុងខួរក្បាល) ហើយប៉ះពាល់ផ្នែកនៃដងខ្លួនដែលគ្រប់គ្រងដោយផ្នែកនៃខួរក្បាលនោះ។ រោគប្រកាច់ដោយទូទៅ ទាក់ទិនខួរក្បាលទាំងមូល ដូច្នេះវាទាក់ទិនរាងកាយទាំងមូល។

### ■ រោគប្រកាច់ដោយផ្នែកសាមញ្ញ

រោគប្រកាច់ដោយផ្នែកសាមញ្ញគឺជារោគប្រកាច់នៅនឹងកន្លែង ដែលប៉ះពាល់ដល់ផ្នែកតែមួយនៃខួរក្បាលប៉ុណ្ណោះ។ រោគសញ្ញាដែលមនុស្សបានជួបប្រទះ គឺអាស្រ័យទៅលើមុខងារដែលផ្នែកនៃខួរក្បាលនោះគ្រប់គ្រង។ រោគប្រកាច់អាចទាក់ទិននឹងចលនាស្វ័យប្រវត្តិ ឬភាពស្ពឹកស្រពន់ដៃជើង មានអារម្មណ៍ដូចបានជួបប្រទះពីពេលមុនៗ ធំក្លិន ឬមានរសជាតិមិនល្អ ឬមានអារម្មណ៍មិនស្រួលក្នុងពោះ ឬចង់ក្អួត។ មនុស្សនោះនៅមានស្មារតីដឹងខ្លួនយ៉ាងពេញលេញនៅពេលកើតរោគប្រកាច់។ ធម្មតា រោគប្រកាច់មានរយៈពេលតិចជា១នាទី បន្ទាប់មកមនុស្សនោះក៏ជាឡើងវិញ។ ពេលណារោគប្រកាច់ដោយផ្នែកឆ្លងរាលដាល ហើយទាក់ទិននឹងខួរក្បាលទាំងមូល គេហៅថារោគប្រកាច់ដោយទូទៅជាបន្ទាប់បន្សំ។



*រោគប្រកាច់ដោយផ្នែក ឬនៅចំកណ្តាលមានប្រភពដើមនៅក្នុងផ្នែកមួយនៃខួរក្បាល។*



*រោគប្រកាច់ដែលចាប់ផ្តើមនៅក្នុងផ្នែកមួយនៃខួរក្បាលអាចឆ្លងរាលដាលទាក់ទិនទៅខួរក្បាលទាំងមូលដើម្បីក្លាយទៅជារោគប្រកាច់ដោយទូទៅជាបន្ទាប់បន្សំ។*



# ការជួយសង្គ្រោះជាបន្ទាន់សំរាប់អ្នកជម្ងឺអង្គុយក្នុងកៅអីមានកង់

ប្រសិនបើនរណាម្នាក់ចាប់ផ្តើមកើតរោគប្រកាច់ក្នុងពេលៈ

- កំពុងអង្គុយជាប់នៅក្នុងកៅអីមានកង់សំរាប់អ្នកជម្ងឺ
- អង្គុយនៅក្នុងរថយន្តចាស់ រថភ្លើង ឬរថភ្លើងក្នុងទីក្រុង
- ដាក់អង្គុយជាប់ទៅនឹងរទេះរុញដាក់កូនង៉ែត ឬរទេះរុញក្មេងជិះ

## សូមនៅឲ្យស្ងៀម ឈប់ ហើយសង្កេតមើល

កុំ សាកល្បងបញ្ឈប់រោគប្រកាច់ឲ្យសោះ។
កុំ ដាក់វត្ថុអ្វីណាមួយទៅក្នុងមាត់របស់មនុស្សនោះ។
កុំ សាកល្បងយកគេចេញពីកន្លែងរបស់គេ - នៅក្នុងករណីយភាគច្រើន កន្លែងអង្គុយអាចផ្តល់នូវការជួយទ្រទ្រង់ខ្លះ។

ទោះជាយ៉ាងណាក៏ដោយ ប្រសិនបើមានអាហារ ទឹក ឬកំអួតនៅក្នុងមាត់របស់មនុស្សនោះ ត្រូវយកមនុស្សនោះចេញពីកន្លែងអង្គុយរបស់គេ ហើយបង្វិលទៅម្ខាងជាបន្ទាន់។

ប្រសិនបើការទាំងនេះពុំអនុវត្តន៍ទេ សូមប្រើសេចក្តីណែនាំដូចបញ្ជាក់នៅកន្លែងនេះ។



## ក្នុងអំឡុងពេលកើតមានរោគប្រកាច់

✓ ការពារមនុស្សនោះដោយកុំឲ្យគេធ្លាក់ ប្រសិនបើពុំមានខ្សែក្រ វ៉ាត់ពាក់ការពារទេ។

✓ ឲ្យប្រាកដច្បាស់ថាកៅអីមានកង់សំរាប់អ្នកជម្ងឺ ឬរទេះក្មេងជិះនៅជាប់នឹងកន្លែង។

✓ ការពារមនុស្សនោះដោយជួយទ្រទ្រង់ក្បាលរបស់គេ។ ដាក់វត្ថុអ្វីមួយដែលទន់នៅពីក្រោមក្បាល ហើយជួយទ្រក្បាល ប្រសិនបើពុំមានប្រដាប់សំរាប់កល់ក្បាលទេ។

✓ ពិនិត្យមើលថាតើលោកអ្នកត្រូវការយកចេញនូវវត្ថុរឹងណាមួយជាពិសេសដែលអាចធ្វើឲ្យឈឺដៃ និងជើង។

✓ ជួនកាលគេប្រហែលត្រូវការយកចេញពីកៅអីមានកង់សំរាប់អ្នកជម្ងឺ នៅពេលឈប់កើតរោគប្រកាច់ ប្រសិនបើរាំងស្ទះដល់ផ្លូវដកដង្ហើម។

ការដឹងខ្លួនឡើងវិញ តាមធម្មតានឹងត្រឡប់មកវិញក្នុងរយៈពេល ២-៣នាទី។ សូមធ្វើឲ្យមនុស្សនោះមានទំនុកទុកចិត្តឡើងវិញ ហើយប្រាប់គេអំពីអ្វីដែលបានកើតមានឡើង។

ព័ត៌មាននេះបានយកលំនាំតាម Epifile: សៀវភៅការគ្រប់គ្រងលើជម្ងឺស្កន់។
Epilepsy Australia។ បោះពុម្ពផ្សាយលើកទី២ ឆ្នាំ២០០៤។